ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

**********

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៧១

ចុះថ្ងៃទី ២៤_០៣_២០០៩

សាលដីកា

លេខ : ១០៤ "ខ"

ចុះថ្ងៃទី ២២_១០_២០១០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១០_២០១០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១៧១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ដែលមានៈ

១- ជនជាប់ចោទឈ្មោះ [redacted] **មេត្រី ហៅ យក្សតូច** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើតនៅសង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ក្រុងភ្នំពេញ [redacted] សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។

២- ជនជាប់ចោទឈ្មោះ [redacted] **សុភា** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទីលំនៅមុនចាប់ [redacted] ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៨-១០-២០០៧ បច្ចុប្បន្ននៅក្រៅឃុំ។

មានលោក [redacted] **ចន្ថា** ជាមេធាវីការពារ។

**ជាប់ចោទពីបទៈ** ប្លន់ (វាយយកប្រាក់ និងខ្សែក) ប្រព្រឹត្តនៅសង្កាត់ផ្សារកណ្តាល ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥០៥ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] **សុភា** ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

<u>**ដំណើររឿងមានដូចតទៅ:**</u>

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១ និង ៣០នាទី នៅចំណុចមាត់ទន្លេផ្លូវ ១៤៤ កែងផ្លូវព្រះស៊ីសុវត្ថ មានជនរងគ្រោះចំនួន ២នាក់ កំពុងអង្គុយលេង ស្រាប់តែមានជនជាប់ចោទចំនួន ៣នាក់ បានធ្វើសកម្មភាពវាយជនរងគ្រោះយកប្រាក់ និងខ្សែក។ ពេលធ្វើសកម្មភាពបានសម្រេចហើយ ជនល្មើសបាននាំគ្នាគេចខ្លួន តែត្រូវកម្លាំងល្បាតនៅក្បែរនោះជួយធ្វើអន្តរាគមន៍ចាប់បានជនល្មើសម្នាក់ឈ្មោះ [redacted] **សុភា** ឯបក្សពួកចំនួន ២នាក់ ទៀត គេចខ្លួន ក្រោយមកសមត្ថកិច្ចស្រាវជ្រាវចាប់បានជនជាប់ចោទឈ្មោះ [redacted] **មេត្រី**។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសឈ្មោះ [redacted] **សុភា** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២៨-១០-២០០៧ ពីបទ ប្លន់ (វាយយកប្រាក់ និងខ្សែក) ប្រព្រឹត្តនៅខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- លើកលែងចោទប្រកាន់លើឈ្មោះ [redacted] **មេត្រី ហៅ យក្សតូច** ភេទប្រុស អាយុ ២០ឆ្នាំ ឱ្យរួចផុតពីបទ ប្លន់ (វាយយកសម្ភារៈ) ប្រព្រឹត្តនៅខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៧ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៣- ទុកសិទ្ធិឱ្យជនរងគ្រោះប្តឹងទាមទារសំណងនៅពេលក្រោយ។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុភា** និងឈ្មោះ [redacted] **មេត្រី** កំបាំងមុខជនរងគ្រោះ ទុកសិទ្ធិឱ្យប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥០៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] **សុភា** ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

<u>**នាពេលសវនាការ**</u>

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] **មេត្រី** បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] **សុភា** ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនសុំឱ្យតុលាការសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួនពិតជាបានប្រព្រឹត្តមែន ដោយពេលប្លន់នោះមានគ្នា ៣នាក់ តែខ្លួនមិនចាំឈ្មោះពេញទេ ចាំតែមានឈ្មោះ **យក្ស**។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សំអាងហេតុរបស់សាលាដំបូងរាជធានីភ្នំពេញមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្តាប់ការសួរដេញដោល ខ្លួនពិនិត្យឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តមែន ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា៖

១- បណ្តឹងឧទ្ធរណ៍លេខ ៥០៥ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុភា ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១ និង ៣០នាទី រំលងអាធ្រាត មានសកម្មភាពវាយជនរងគ្រោះយកប្រាក់ និងខ្សែក នៅចំណុចមាត់ទន្លេ សង្កាត់ផ្សារកណ្តាល ២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ប្រព្រឹត្តដោយក្រុមជនល្មើសឈ្មោះ [redacted] សុភា។ ករណីនេះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួន និងបក្សពួកពិតជាបានធ្វើសកម្មភាពវាយជនរងគ្រោះយកប្រាក់ ខ្សែក ប្រាកដមែន។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅសង្កាត់ផ្សារកណ្តាល ២ ខណ្ឌដូនពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥០៥ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] **សុភា** ជាជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០៥ (ក្រ៤) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០១១

**ក្រឡាបញ្ជី**

[illegible]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

234